# សម្តីចុងក្រោយ

ថ្ងៃទី ៣០ មិនា ឆ្នាំ២០១១

ដោយ ឆាល់ បេកសាន់

ប្រែសម្រួលដោយ ទែន សុខស្រីនិត

ថ្ងៃនេះគឺជាថ្ងៃចុងបញ្ចប់នៃបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ (ហៅ ឌុច) នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ។ សាលអង្គសវនាការសាធារណៈពោលពេញទៅដោយប្រជាជនកម្ពុជាជាច្រើនដែលនេះបានឆ្លុះបញ្ចាំងពីប្រធានបទដដែកដដែលក្នុងឆ្នាំនេះស្តីពីបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណីដែលផ្តោតទៅលើបណ្តឹងដែលថាអង្គបុរេជំនុំជម្រះតុលាការដំបូងមិនបានបំពេញភារកិច្ចរបស់ខ្លួនក្នុងការផ្តល់ការសងថ្លៃខូចខាតឲ្យបានគ្រប់គ្រាន់ដល់ជនរងគ្រោះរបបខ្មែរក្រហម ។ យ៉ាងណាមិញ អ្វីដែលគួរឲ្យចងចាំជាងគេបំផុតនោះនៅក្នុងថ្ងៃនេះគឺការនិយាយចុងក្រោយរបស់ ឌុច ដែលជាការស្នើសុំដ៏ឈ្លាសវៃ និងមានរបៀបដើម្បីសុំដោះលែងខ្លួនដែលបណ្តាលឲ្យសំណុំរឿង០០១មកឡើងដោះស្រាយរឿងក្តីម្តងទៀតនៅថ្ងៃនេះ ។

## បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី

ថ្ងៃនេះក្រុមដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗមានឱកាសឡើងនិយាយនៅក្នុងអង្គសវនាការនិងលើកបង្ហាញបណ្តឹងឧទ្ធរណ៍របស់ខ្លួនទាក់ទងទៅនឹងការចូលរួម និងសំណងថ្លៃខូចខាតរបស់ជនរងគ្រោះ ។ មាតិកាសំខាន់បីរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីគឺថាអង្គជំនុំជម្រះសាលាដំបូង ១) យល់ខុសលើវិធានផ្ទៃក្នុងដោយបង្កើតឲ្យមានការពិនិត្យមើលឡើងវិញលើការទទួលយកពាក្យស្នើសុំជាដើមបណ្តឹងរដ្ឋប្បវេណី ២) មានកំហុសឆ្គងដោយអនុវត្តបទដ្ឋានទទួលយកពាក្យស្នើសុំជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានកម្រិតខ្ពស់ហួសហេតុ និង៣) អាក់ខានមិនបានផ្តល់សំណងថ្លៃខូចខាតឲ្យបានគ្រប់គ្រាន់ដល់ជនរងគ្រោះ ។

លោក ការីម ខាន់ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ បានចាប់ផ្តើមលើអំណះអំណាងរបស់ក្រុមខ្លួនដោយស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ផលប៉ះពាល់នៃរោគតានតឹងផ្លូវចិត្តដែលមានមកលើជនរងគ្រោះដែលបណ្តាលមកពីការសម្រេចចិត្តរបស់អង្គជំនុំជម្រះតុលាការដំបូងដែលបានច្រានចោលពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនៅថ្ងៃអានសាលក្រម ។ «បន្ទាប់ពីរងទុក្ខអស់រយៈពេលជាច្រើនខែក្នុងអំឡុងពេលវិនិច្ឆ័យទោស ឌុច បន្ទាប់ពីបានធ្វើអ្វីៗគ្រប់យ៉ាងដែលពួកគេតម្រូវឲ្យធ្វើមក នៅថ្ងៃប្រកាសសាលក្រមជាលើកដំបូង ដើមបណ្តឹងរដ្ឋប្បវេណីបែរជាត្រូវបានបដិសេធមិនទទួលស្គាល់ជាឋានៈដើមបណ្តឹងរដ្ឋប្បវេណីជាផ្លូវការទៅវិញ» ។ លោកបានតវ៉ាថា គ្មានវិធានណាមួយនៅក្នុងវិធានផ្ទៃក្នុងដែលបញ្ជាក់ថាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការអនុវត្តការពិនិត្យមើលឡើងវិញលើលក្ខខណ្ឌ(sic)លក្ខន្តិកៈធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់នោះទេ ។ បទដ្ឋាននេះត្រូវបាន«ប្រឌិតឡើង» ដោយអង្គជំនុំជម្រះសាលាដំបូងតែម្តង ។

មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុមផ្សេងទៀតបានគាំទ្រអំណះអំណាងនេះ ហើយបានអះអាងថាសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបានធ្វើឲ្យមានការដកហូតសិទ្ធិរបស់កូនក្ដីរបស់ខ្លួន ។ ជាក់ស្ដែង កូនក្ដីទាំងអស់បានពឹងផ្អែកលើការទទួលស្គាល់ឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីលើកដំបូងរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងអំឡុងអង្គវិនិច្ឆ័យទោសរបស់ ឌុច នេះ ។ ចៅក្រម កូណូរីកកា មីឡាត បានសម្ដែងភាពអាណិតអាសូរដល់ដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានបដិសេធចោលដោយអង្គជំនុំជម្រះសាលាដំបូងប៉ុន្តែបានចោទជាចម្ងល់ថាតើការបំពេញទៅតាមការរំពឹងទុករបស់ដើមបណ្ដឹងរដ្ឋប្បវេណីជាការទទួលខុសត្រូវរបស់អ្នកណា ។ លោកស្រីចៅក្រមក៏បានគូសបញ្ជាក់ថានីតិវិធីដើមបណ្ដឹងរដ្ឋប្បវេណីរបស់ក្រមកម្ពុជាក៏មានបញ្ចូលការពិនិត្យមើលឡើងវិញលើកទីពីរលើពាក្យស្នើសុំធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណីដែរដោយធ្វើការគាំទ្រលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ។

ទាក់ទិននឹងកំហុសឆ្គងផ្លូវច្បាប់វិញ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីតវ៉ាថាអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តភ័ស្តុតាងដាក់បន្ទុកដែលមានកម្រិតខ្ពស់ហួសហេតុនៅពេលដែលសម្រេចថាដើមបណ្ដឹងរដ្ឋប្បវេណីខ្លះមិនបានបង្ហាញភ័ស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់ថាខ្លួនជាសាច់ញាតិរបស់អ្នកទោសដែលបានសម្លាប់នៅមន្ទីរស-២១ ។

មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុមពីរ និងបី ក៏បានលើកឡើងពីបញ្ហាទាក់ទងនឹងសំណងថ្លៃខូចខាតរបស់អង្គជំនុំជម្រះសាលាដំបូងដែលនៅមានកម្រិតមិនសមរម្យក្នុងការសម្រេចដាក់បញ្ចូលឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសាលក្រម និងលើគេហទំព័ររបស់តុលាការ ។ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើការស្នើសុំជាច្រើនដូចជា ការសាងសង់បូជានីយដ្ឋាន ការបោះពុម្ព និងការផ្សព្វផ្សាយការសម្ដែងវិប្បដិសាររបស់ ឌុច និងការផ្ដល់ជាសេវាថែទាំសុខភាពសម្រាប់ជនរងគ្រោះដែលកំពុងតែទទួលរងគ្រោះថ្នាក់ផ្នែកសតិអារម្មណ៍ និងរូបរាងកាយ ។

ដោយអាក់អន់ចិត្តចំពោះមូលនិធិដែលតុលាការបានផ្ដល់ឲ្យដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រី ស៊ីលគិ ស្ទូតហ្ស៊ីនស្គី មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម២ បានសម្ដែងនូវអារម្មណ៍មិនពេញចិត្តចំពោះសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលមិនបានឲ្យ ឌុច ផ្ដល់សំណងថ្លៃខូចខាតដល់ជនរងគ្រោះដោយផ្ទាល់ ។ លោកស្រីបានសួរថាហេតុអ្វីបានជាសាលាក្ដីខ្មែរក្រហម សន្មតថា ឌុច មានជីវភាពក្រីក្រ ដោយលើកឡើងថា ឌុច បានរកកម្រៃពីការលក់ប្រវត្តិរូបរបស់ ខ្លួន និងចូលរួមថតខ្សែភាពយន្តរឿង«ពេជ្ឈឃាតចុងក្រោយ» ។

លោកស្រី ស្ទូដហ្ស៊ីនស្គី បានសោកស្ដាយដែលថាអង្គសវនាការនេះគឺជាពេលចុងក្រោយបង្អស់ដែលមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីអាចបំពេញតួនាទីរបស់ខ្លួនដោយឯករាជ្យ ។ វិធានផ្ទៃក្នុង១២ស្ទួនដែលទើបតែនឹងបង្កើតឡើងនោះចាត់ឲ្យមានតែមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីតែពីររូបប៉ុណ្ណោះ ចាត់តាំងឲ្យមេធាវីទាំងពីររូបនេះ«ធ្វើជាតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីដទៃទៀតនៅក្នុងអង្គសវនាការ និងផ្ដល់នូវ«ការទទួលខុសត្រូវខ្ពស់ឲ្យមេធាវីទាំងពីររូបនេះ លើការស្វែងរកមតិគាំទ្រភាគច្រើនយុត្តិសាស្ត្រនិងការធ្វើបទបង្ហាញតំណាងឲ្យក្រុមដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងអំឡុងអង្គសវនាការ» ។

## សេចក្តីសន្និដ្ឋានបញ្ចប់របស់ ឌុច

អង្គសវនាការសម្រាប់សំណុំរឿង០០១ទាំងអស់ត្រូវបានបញ្ចប់នៅក្នុងថ្ងៃនេះដោយការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ពី ឌុច ដែល ឌុច បានព្យាយាមបង្ហាញនូវវិប្បដិសារីសម្រាប់ឧក្រិដ្ឋកម្មរបស់ខ្លួន និងស្នើសុំឲ្យមានការដោះលែងឲ្យរួចទោស ។ ឌុច បានចាប់ផ្តើមឡើងដោយសង្កត់ធ្ងន់គោលជំហរចម្បងរបស់ខ្លួនថា សាលាក្តីខ្មែរក្រហមមិនមានយុត្តាធិការផ្នែកបុគ្គលដើម្បីកាត់ទោស ឌុច ទេ ពីព្រោះ ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬជាជនដែលមានការទទួលខុសត្រូវខ្ពស់ សម្រាប់ឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមនោះទេ ។ ឌុច បានប្រឆាំងនឹងការអះអាងរបស់ព្រះរាជអាជ្ញាដែលបានចាត់ទុកមន្ទីរស-២១ជាផ្នែកមួយដ៏សំខាន់របស់គណៈកម្មាការអចិន្ត្រៃយ៍ ។ ឌុច បានចាត់ទុកខ្លួនឯងជាកម្មាភិបាលថ្នាក់កណ្តាល ហើយបាននិយាយថា “មន្ទីរស-២១មិនមែនខុសប្លែកគ្នា ពីមន្ទីរសន្តិសុខ ផ្សេងទៀតឡើយ ។ វាគឺមានស្ថានភាពដូចគ្នា និងមន្ទីរសន្តិសុខផ្សេងទៀតដែលមានការអនុវត្តការ ធ្វើទារុណកម្ម លើអ្នកទោស” ។ បន្ទាប់មកទៀត ឌុច បានផ្លាស់ប្តូរ មកលើកឡើងពីករណីការប្រព្រឹត្តឧក្រិដ្ឋកម្ម ក្រោមការបង្ខិតបង្ខំដោយនិយាយថាខ្លួនបានរួចរស់រានមានជីវិតពីរបបខ្មែរក្រហមដោយសារតែខ្លួនបាន“អនុវត្តទៅតាមបញ្ជាថ្នាក់លើយ៉ាងខ្ជាប់ខ្ជួន” ។ ជាមួយគ្នានេះ ឌុច ក៏បានអះអាងថាខ្លួន បានបំពេញតួនាទីជាសាក្សីដែលសហការ និងដែលមានវិប្បដិសារី ។ នេះគឺជាការអះអាងមួយដែលមិនសមហេតុផល បើយើងពិចារណាពីការប្រានចោលមិនទទួលកំហុសនិងការស្នើ សុំឲ្យដោះលែងរួចពីទោសដែលធ្វើឡើងដោយ ឌុច” ។ “ខ្ញុំសូមសម្តែងនូវវិប្បដិសារីចំពោះ ជនរងគ្រោះ ហើយសូមការលើកលែងទោស... ជាចុងក្រោយ ខ្ញុំសូមលើកឡើងពីគោលការណ៍របស់ខ្ញុំថា ខ្ញុំមិនមែនជាជនដែលឋិតនៅក្រោមយុត្តាធិការផ្នែកបុគ្គលរបស់តុលាការឡើយ” ។